Co-funded by the European Union

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

Implemented by

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

ការផ្តល់សេវាកាន់តែប្រសើរដូនប្រជាពលរដ្ឋនៅក្នុងខេត្តបាត់ដំបង

ការអនុវត្តនានាដែលបានជ្រើសរើសពីស្រុកជាដៃគូរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (អ៊ីយូដា)

បោះពុម្ពដោយ៖	GIZ	ទទួលខុសត្រូវដោយ៖	លោកស្រី Maraile Goergen maraile.goergen@giz.de
	ការិយាល័យកណ្តាល ទីក្រុងបុន និងអ៊ីចប៊ិន ប្រទេសអាល្លឺម៉ង់ គម្រោងសហភាពអឺរ៉ុប សម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (អ៊ីយូដា) **ការិយាល័យនៅភ្នំពេញ** ផ្ទះលេខ១៦៨ អេ ផ្លូវ២៧៨ សង្កាត់ចឹងកេងកង ១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ទូរស័ព្ទលេខ៖ + ៨៥៥ ២៣ ២១ ៦៧ ៥៦ **ការិយាល័យនៅខេត្តបាត់ដំបង** សាលាខេត្តបាត់ដំបង ផ្លូវលេខ ១ ទល់មុខស្ពានចាស់ ខេត្តបាត់ដំបង ប្រទេសកម្ពុជា ទូរស័ព្ទលេខ៖ + ៨៥៥ ៥៣ ៧៣១ ២៦2 Facebook: https://www.facebook.com/eudarproject Website: www.giz.de www.eeas.europa.eu/cambodia www.bmz.de/en/index.html		
		រូបថតដោយ៖	គម្របមុខ និងទំព័រទី៣៖ លោក Miguel Jerónimo ទំព័រផ្សេងទៀត៖ អ៊ីយូដា រាជធានីភ្នំពេញ ខែមីនា ឆ្នាំ ២០១៩

គម្រោងនេះសហការផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (BMZ)។

ឯកសារនេះ ត្រូវបានបោះពុម្ពផ្សាយ ក្រោមការឧបត្ថម្ភថវិកាដោយសហភាពអឺរ៉ុប។ ខ្លឹមសារក្នុង អត្ថបទនេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។

ការស្វែងយល់ពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (អ៊ីយូដា)

សិទ្ធអំណាចផ្នែករដ្ឋបាល និងផ្នែកនយោបាយនៅក្នុងប្រទេសកម្ពុជា បានប្រមូលផ្តុំនៅរដ្ឋាភិបាលថ្នាក់កណ្តាលអស់រយៈពេលជាច្រើនឆ្នាំមកហើយ។ ប៉ុន្តែបច្ចុប្បន្ន ប្រទេសនេះកំពុងស្ថិតនៅក្នុងដំណាក់កាលនៃការកែសម្រួល ដែលក្នុងនោះរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល និងនីតិវិធីរដ្ឋបាល កំពុងត្រូវបានកែសម្រួលឱ្យស្របតាមតម្រូវការរបស់ប្រទេសដែលតម្រង់ទិសដល់ការអភិវឌ្ឍន៍។ រាជរដ្ឋាភិបាលកម្ពុជា កំពុងប្រឹងប្រែងធ្វើការលើកកម្ពស់វប្បធម៌សេវាសាធារណៈ និងឆន្ទៈម្ចាស់ការ ព្រមទាំងជំនាញនានាសម្រាប់ស្ថាប័នសាធារណៈ ក៏ដូចជាមន្ត្រីរបស់ខ្លួន ដើម្បីធ្វើឱ្យរដ្ឋបាលសាធារណៈ កាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល ទទួលបានភាពជឿជាក់ និងមានភាពឆ្លើយតបទាន់ពេលវេលាទៅតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ។

ដើម្បីរៀបចំឱ្យរដ្ឋបាលមូលដ្ឋានមានស្វ័យភាពបាន ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ព្រមទាំងសិទ្ធិអំណាចខាងធ្វើសេចក្តីសម្រេចចិត្តនានា ត្រូវផ្ទេរជាបណ្តើរៗទៅឱ្យរដ្ឋបាលមូលដ្ឋាន។ ទោះបីជាមានការប្រឹងប្រែងទាំងនេះក្តី ក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ នៅមិនទាន់មានបទពិសោធន៍ ជំនាញ និងបុគ្គលិក ដែលជាតម្រូវការចាំបាច់សម្រាប់រៀបចំគោលនយោបាយនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួននៅឡើយ។ ដោយសារសិទ្ធអំណាចនិងស្វ័យភាពរបស់ក្រុមប្រឹក្សាមានដែនកំណត់ ក៏ដូចជាការសម្របសម្រួលមិនទាន់មានគ្រប់គ្រាន់ បានធ្វើឱ្យក្រុមប្រឹក្សានិងរដ្ឋបាលរបស់ខ្លួន មានការលំបាកក្នុងការអនុវត្តនូវមុខងារ និងភារកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព និងគណនេយ្យភាព ដែលកត្តាទាំងនេះបានធ្វើឱ្យការផ្តល់សេវាសាធារណៈមិនទាន់មានប្រសិទ្ធភាព។

មន្ត្រីនៃការិយាល័យច្រកចេញចូលតែមួយក្នុងក្រុងបាត់ដំបង ផ្តល់សេវាដល់ពលរដ្ឋដែលមានសំណួរ ប្រកបដោយភាពរួសរាយរាក់ទាក់

ប្រជាពលរដ្ឋលើកពីការបារម្ភរបស់ខ្លួនក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ក្នុងស្រុកបាណន់

គោលបំណងរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលដែលបានទទួលថវិកាពីក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (BMZ) និងចូលរួមផ្តល់មូលនិធិដោយសហភាពអឺរ៉ុប និងអនុវត្តដោយ GIZ គឺរដ្ឋបាលមូលដ្ឋានផ្តល់សេវាកាន់តែប្រសើរដល់ប្រជាពលរដ្ឋ។ ឆ្លើយតបនឹងគោលបំណងនេះ រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សា និងការិយាល័យជំនាញនានា នៅក្នុងស្រុក និងក្រុងជាដៃគូ ក្នុងខេត្តកណ្តាល និងខេត្តបាត់ដំបង ត្រូវបានផ្តល់សិទ្ធិអំណាចឱ្យផ្តល់សេវាសាធារណៈដែលបានជ្រើសរើស ឱ្យប្រកបដោយភាពសម្របសម្រួល ភាពឆ្លើយតប និងគណនេយ្យភាព។

ដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានធ្វើការសហការជាមួយ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួងវិស័យនានានៅថ្នាក់ជាតិ ក្នុងរាជធានីភ្នំពេញ។ នៅថ្នាក់ក្រោមជាតិ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់សមាជិកក្រុមប្រឹក្សា ដែលមកពី ១២ ស្រុក និង ១ ក្រុងនៃខេត្តកណ្តាល និងខេត្តបាត់ដំបង ដើម្បីធ្វើឱ្យពួកគេមានសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈកាន់តែប្រសើរដល់ប្រជាពលរដ្ឋ។ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ក៏បានពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យពួកគេអាចធ្វើការសាកល្បង និងអនុវត្តយន្តការនានា ក្នុងការផ្តល់សេវាសាធារណៈ ឱ្យប្រកបដោយភាពឆ្លើយតប និងគណនេយ្យភាព តាមដែលអាចធ្វើទៅបាន។ តាមរយៈវិធីសាស្ត្រនេះ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់យោបល់ដល់ស្រុក និងក្រុងដៃគូនានា ក្នុងការអនុវត្តសិទ្ធិផ្តួចផ្តើមគំនិតរបស់ខ្លួនដែលជាផ្នែកមួយនៃអាណត្តិទូទៅរបស់ក្រុមប្រឹក្សាស្រុក និងក្រុង។ ការអនុវត្តសិទ្ធិផ្តួចផ្តើមគំនិតនេះ ក៏បានចូលរួមចំណែកពង្រឹងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចសម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិផងដែរ។

លើសពីនេះទៀត គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ក៏បានគាំទ្រដល់ការពង្រីកការិយាល័យច្រកចេញចូលតែមួយ ដែលជាការិយាល័យផ្តល់សេវាជាច្រើនដល់ប្រជាពលរដ្ឋ នៅកន្លែងតែមួយនៅតាមស្រុកបន្ថែមទៀត។ គម្រោងនេះ ក៏ជួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងការិយាល័យជំនាញនានាដែលបានជ្រើសរើសនៅថ្នាក់ក្រុង ស្រុក ដើម្បីឱ្យពួកគេធ្វើការសហការជាមួយគ្នាឱ្យបានកាន់តែប្រសើរ។ រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សា ក៏ត្រូវបានពង្រឹងសមត្ថភាពផងដែរ ដើម្បីឱ្យពួកគេអាចគ្រប់គ្រងបុគ្គលិករបស់ខ្លួនឱ្យប្រកបដោយភាពសម្របសម្រួល និងទទួលបានគុណផលល្អ។ ដើម្បីសម្រេចបានគោលបំណងខាងលើនេះ ឧបករណ៍ថ្មីៗសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ដូចជា ការពិពណ៌នាមុខតំណែង និងការវាយតម្លៃគុណផលជាប្រចាំ កំពុងត្រូវបានរៀបចំដាក់ឱ្យសាកល្បង និងអនុវត្តជាក់ស្តែងនៅក្នុងកន្លែងធ្វើការ។ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការនិងរដ្ឋបាលក៏គាំទ្រផងដែរលើការធ្វើកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងដំណើរការរៀបចំសម្រាប់ការផ្ទេរមុខងារជាកាតព្វកិច្ចនៅក្នុងវិស័យសុខាភិបាល និងវិស័យអប់រំ ពីការិយាល័យជំនាញនានានៅថ្នាក់ជាតិ ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ចុងបញ្ចប់ គម្រោងនេះបានផ្តោតលើការយកចិត្តទុកដាក់ជាពិសេស ក្នុងការកត់ត្រាមេរៀនបទពិសោធន៍ពីដំណើរការគាំទ្រនានាខាងលើ ដែលទាំងអស់នេះគឺផ្អែកលើយុទ្ធសាស្ត្របែបនយោបាយ។ មេរៀនបទពិសោធន៍ទាំងនេះនឹងត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ ដើម្បីលើកកម្ពស់ការអនុវត្តសាកល្បង និងជំរុញដំណើរការវិមជ្ឈការនៅក្នុងប្រទេសកម្ពុជាឱ្យដើរទៅមុខ។ កត្តានេះជួយគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលក្រោមជាតិឱ្យកាន់តែប្រកបដោយភាពឆ្លើយតបបង្កើនគុណផលការងាររបស់មន្ត្រីរាជការស៊ីវិលដែលបម្រើការងារនៅថ្នាក់ក្រោមជាតិ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានយ៉ាងរហ័ស និងប្រកបដោយប្រសិទ្ធភាព។

ជាលទ្ធផលនៃការគាំទ្ររបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ចំនួននៃការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា ដែលទាក់ទងទៅនឹងតម្រូវការប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងអំឡុងពេលកិច្ចប្រជុំក្រុមប្រឹក្សា ព្រមទាំងការផ្តល់សេវាមួយចំនួន ដែលបានជ្រើសរើស ដូចជា ការគ្រប់គ្រងសំរាមសំណល់រឹង និងសេវាផ្សេងៗទៀតដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយបានកើនឡើងនៅក្នុងខេត្តជាដៃគូទាំងពីរ គឺខេត្តបាត់ដំបង និងខេត្តកណ្តាល។ នៅក្នុងសៀវភៅព្រឹត្តិបត្ររឿងជោគជ័យក្បាលទី២នេះ យើងចង់ណែនាំពីសមិទ្ធិផលថ្មីៗ និងធ្វើការសិក្សាបន្ថែមពីមេរៀនទាក់ទងនឹងការផ្តល់សេវា។

ការចូលរួមរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល មានខេត្តជាដៃគូចំនួន ២ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺខេត្តកណ្តាល និងខេត្តបាត់ដំបង។ ខេត្តកណ្តាលជាប្រភេទខេត្តដែលមានលក្ខណៈបែបជាទីក្រុង ដែលស្ថិតនៅជុំវិញរាជធានីភ្នំពេញ។ ចំណែកខេត្តបាត់ដំបង ជាខេត្តបែបជនបទ ដែលមានព្រំប្រទល់ជាប់ជាមួយប្រទេសថៃ និងខេត្តជនបទផ្សេងៗទៀត ស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ នៅខេត្តកណ្តាល គម្រោងបានធ្វើការជាមួយស្រុកជាដៃគូចំនួន ៣ និងនៅខេត្តបាត់ដំបង ធ្វើការជាមួយស្រុកចំនួន ៩ និងក្រុងចំនួន ១។ ជារួម ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋាន ចំនួន ១១នាក់ របស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានធ្វើការដោយផ្ទាល់ ជាមួយដៃគូពាក់ព័ន្ធទាំងអស់នៅក្នុងស្រុកជាដៃគូ និងគាំទ្រដោយប្រយោល និងដោយផ្ទាល់ដល់៖

ទិន្នន័យស្ថិតិក្នុងទំព័រនេះ និងទំព័របន្ត បន្ទាប់គឺផ្អែកលើប្រភពទាំងនេះ៖ ទិន្នន័យអំពីភាពក្រីក្រ យកចេញពីរបាយការណ៍ប្រៀបធៀបភាពក្រីក្រ ឆ្នាំ២០១៣ របស់ក្រសួងផែនការ។ ទិន្នន័យអំពីពលរដ្ឋ និងមុខរបរយកចេញពីទិន្នន័យស្រុកឆ្នាំ២០១៦ របស់មន្ទីរផែនការខេត្តបាត់ដំបង និង ខេត្តកណ្តាល។ ទិន្នន័យអំពីក្រុមប្រឹក្សា យកចេញពីអនុក្រិត្យ ស្តីពីការទទួលស្គាល់សមាជិកក្រុមប្រឹក្សាស្រុក ក្រុង អាណត្តិទី ២ នៃក្រុមប្រឹក្សាស្រុក ក្រុង

ក្រុមប្រឹក្សាស្រុក ក្រុង ចំនួន ២៧២ នាក់
ដែលក្នុងនោះ មាន ៤៥ នាក់ ជាស្ត្រី

ប្រជាពលរដ្ឋចំនួន ១.៦៤៤.000 នាក់ ដែល ៤0% គឺជាកុមារ
និងក្មេងវ័យជំទង់ដែលមានអាយុក្រោម ១៨ ឆ្នាំ[9]

ខេត្តនានានៃព្រះរាជាណាចក្រកម្ពុជា

9. ចូរកត់សម្គាល់ថា ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានចំនួន ២រូប ធ្វើការជាមួយស្រុកចំនួន២។

ខេត្តបាត់ដំបង

ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានចំនួន ៨រូបរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ធ្វើការផ្ទាល់នៅក្នុងសាលាស្រុក និងក្រុងជាដៃគូរបស់ខ្លួនរៀងៗខ្លួន ដើម្បីផ្តល់យោបល់ ប្រឹក្សាយោបល់ និងបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សា រដ្ឋបាល និងបុគ្គលិកការិយាល័យជំនាញ ជារៀងរាល់ថ្ងៃ។ ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានម្នាក់ៗ បានប្រើប្រាស់វិធីសាស្ត្រប្រឹក្សាយោបល់ ដោយបត់បែនទៅតាមតម្រូវការជាក់ស្តែងរបស់ក្រុង ស្រុកនីមួយៗ ដើម្បីឱ្យក្រុង ស្រុកជាដៃគូមានសមត្ថភាពក្នុងការផ្តល់សេវាសាធារណៈកាន់តែប្រសើរ។

ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានម្នាក់ៗ ត្រូវទទួលខុសត្រូវ ក្នុងការធានាឱ្យកិច្ចសហប្រតិបត្តិការនៅក្នុងស្រុកជាដៃគូរបស់ខ្លួន និងកិច្ចសហប្រតិបត្តិការនៅក្នុងស្រុកផ្សេងៗទៀត ដែលមិនបានទទួលការគាំទ្រផ្នែកបច្ចេកទេសពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល នៅក្នុងខេត្តតែមួយ ប្រព្រឹត្តទៅដោយរលូន។ ស្រុកផ្សេងៗទៀត ដែលមិនបានទទួលការគាំទ្រផ្នែកបច្ចេកទេសពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល អាចបានទទួលប្រយោជន៍តាមរយៈការបណ្តុះបណ្តាលដោយផ្អែកតាមតម្រូវការជាក់ស្តែង និងវេទិកាផ្លាស់ប្តូរមេរៀនបទពិសោធន៍ដែលរៀបចំឡើងជាប្រចាំរវាងខេត្តកណ្តាល និងខេត្តបាត់ដំបង ក៏ដូចជា ស្ថាប័នជាដៃគូនៅថ្នាក់ជាតិ រួមមាន លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងមុខងារសាធារណៈ[២]។

ក្រៅពីការផ្តល់ការប្រឹក្សាយោបល់ ទីប្រឹក្សារបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ក៏ជួយសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធផ្សេងៗផងដែរ ក្នុងការរៀបចំវេទិកាផ្លាស់ប្តូរយោបល់លើប្រធានបទផ្សេងៗជាច្រើន ដើម្បីជំរុញការរៀនសូត្រទៅវិញទៅមក និងការពិភាក្សាលើគោលនយោបាយនានា ដែលកត្តានេះនឹងជួយឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ទទួលបានគំនិតថ្មីៗ ដើម្បីកែលម្អការផ្តល់សេវារបស់ខ្លួនឱ្យកាន់តែល្អប្រសើរ។ ជាមួយនឹងវិធីសាស្ត្រនេះ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល នៅក្នុងខេត្តបាត់ដំបង បានគាំទ្រដោយផ្ទាល់ និងដោយប្រយោល ទៅដល់៖

ក្រុមប្រឹក្សាស្រុក ក្រុង ចំនួន ២២៥ នាក់
ដែលក្នុងនោះ មាន ៣៦ នាក់ ជាស្ត្រី

ប្រជាពលរដ្ឋ ជិត ១.២៤៣.០០០ នាក់
ដែលក្នុងនោះ ៤0% ជាកុមារ និងក្មេងវ័យជំទង់

បន្ថែមទៅលើការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់មូលនិធិឧបត្ថម្ភធនខ្នាតតូចដល់ក្រុង ស្រុកដៃគូរបស់ខ្លួន ដើម្បីផ្តល់សេវាសង្គម ដែលជាមុខងារជាអាណត្តិទូទៅរបស់ក្រុមប្រឹក្សា។ សេវាសង្គមទាំងនេះ ត្រូវបានផ្តល់ដោយយោងតាមសំណើសុំរបស់ប្រជាពលរដ្ឋ និងត្រូវបានចាត់អាទិភាពដោយក្រុមប្រឹក្សានៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ខ្លួន ដើម្បីពិភាក្សារក

២. ទីប្រឹក្សាផ្នែកគោលនយោបាយចំនួន ០៣រូប របស់ គម្រោងអ៊ីយូដាសហការ និងប្រចាំការនៅស្ថាប័នដៃគូនៅថ្នាក់ជាតិ ដែលរួមមានលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមុខងារសាធារណៈជារៀងរាល់ថ្ងៃ។ សេវាប្រឹក្សាយោបល់ និង ការសម្របសម្រួលក្នុងការតាក់តែង និងពិភាក្សាគោលនយោបាយត្រូវបានធ្វើឡើងក្នុងចំណោមអ្នកពាក់ព័ន្ធមកពីក្រសួងផ្សេងៗ និងរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

ដំណោះស្រាយនានា។ នៅខេត្តបាត់ដំបងសំណូមពរភាគច្រើនរបស់ប្រជាពលរដ្ឋ ដែលទាមទារឱ្យក្រុមប្រឹក្សាចាត់វិធានការដោះស្រាយ មានចំនួន ៣សំខាន់ៗ។ ទី១ គឺបញ្ហាអនាម័យសាធារណៈ ជាពិសេសបញ្ហាដែលធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់កុមារ ទី២គឺបញ្ហាការគ្រប់គ្រងសំរាម សំណល់រឹង និងការថែរក្សាកន្លែងសាធារណៈ និងទី៣ គឺសំណូមពរសម្រួលនិតិវិធីរដ្ឋបាល និងកែលម្អ ការផ្តល់សេវានៅតាមការិយាល័យរដ្ឋបាលមូលដ្ឋាន។

ខេត្តបាត់ដំបង

ការអនុវត្តនានាស្តីពីការផ្តល់សេវាល្អរបស់ស្រុកជាដៃគូនៅក្នុងខេត្តបាត់ដំបង

សម្រាប់ខេត្តបាត់ដំបង មានឧទាហរណ៍គំរូចំនួន៧ ដែលស្រុក និងក្រុងជាដៃគូ បានខិតខិតប្រឹងប្រឹងផ្តល់សេវាជូនប្រ ជាពលរដ្ឋបានល្អប្រសើរ ត្រូវបានជ្រើសរើសសម្រាប់ដាក់បង្ហាញនៅក្នុងសៀវភៅព្រឹត្តិបត្រនេះ។ នៅក្នុងឧ ទាហរណ៍គំរូទី១នេះ គឺកើតឡើងនៅក្នុងស្រុកបវេល ដែលផ្សារគ្មានសណ្តាប់ធ្នាប់ ត្រូវបានក្រុមប្រឹក្សាសម្រេចដាក់ឱ្យរៀបចំឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវឡើងវិញ ប្រកបដោយជោគជ័យ។ នៅក្នុងស្រុករតនមណ្ឌល និងស្រុកសំឡូត ស្តង់ដារសុខភាពសម្រាប់ចំណីអាហារ និងភេសជ្ជៈដែលបានលក់នៅក្នុងសាលារៀន ត្រូវបានរៀបចំបង្កើតឡើងប្រកបដោយជោគជ័យ។ ស្រុកមោងឫស្សី និងក្រុងបាត់ដំបង បានផ្តល់សេវារដ្ឋបាលកាន់តែល្អប្រសើរជាងមុន តាមរយៈការអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងគុណផល ដែលរៀបចំបង្កើតឡើងដោយក្រសួងមុខងារសាធារណៈ ក្នុងគោលបំណងដើម្បីបង្កើនគុណផលការងាររបស់មន្ត្រីរាជការស៊ីវិល។ ស្រុកបាណន់ បានចូលរួមដោះស្រាយបញ្ហាសំរាម សំណល់រឹងដ៏ធ្ងន់ធ្ងររបស់ស្រុក ហើយបានធ្វើឱ្យស្រុកប្រែក្លាយជាកន្លែងមានអនាម័យស្អាតដ៏គួរឱ្យកត់សម្គាល់។ ចំណែកចុងក្រោយស្រុកថ្មគោល ក្រុមប្រឹក្សាមានសមត្ថភាពក្នុងការឆ្លើយតបនឹងតាមតម្រូវការរបស់ប្រជាពលរដ្ឋ។ នៅក្នុងទំព័របន្ទាប់ សមិទ្ធិផលទាំងនេះនឹងត្រូវបានបង្ហាញ។

ការលើកកម្ពស់ការយល់ដឹង និងការកែលម្អសណ្តាប់ធ្នាប់ផ្សារនៅក្នុងស្រុកបវេល

ជាយូរលង់ណាស់មកហើយ ផ្សារនៅក្នុងស្រុកបវេលដែលស្ថិតនៅតាមបណ្តោយផ្លូវជាតិ ត្រូវបានគេស្គាល់ថាជាកន្លែងរញ៉ៃរញ៉ៃ និងគ្មានសណ្តាប់ធ្នាប់។ ដោយមានការកើនឡើងនូវចំនួនអ្នកលក់ដូរ តូបលក់ទំនិញ ក៏ដូចជាសម្ភារបរិក្ខារនានា បានដាក់រំលោភមកលើផ្លូវថ្នល់ដែលមានយានជំនិះជាច្រើនកំពុងធ្វើចរាចរណ៍។ យានជំនិះនានាដែលឆ្លងកាត់ផ្សារនេះ ចាំបាច់ត្រូវតែបន្ថយល្បឿន ដោយសារការលក់ និងទិញទំនិញនៅលើផ្លូវ។ កត្តានេះបានបណ្តាលឱ្យមានការកកស្ទះចរាចរណ៍ជារៀងរាល់ថ្ងៃ ហើយជួនកាលក៏បានធ្វើឱ្យខូចខាតដល់តូបលក់ទំនិញខ្លះផងដែរ។ លើសពីនេះ អាជីវករ ដែលលក់ទំនិញនៅក្នុងផ្សារក៏មកឈ្លោះប្រកែកគ្នាជាមួយនឹងអាជីវករដែលលក់ទំនិញនៅក្រៅផ្សារ ដែលស្ថិតនៅលើថ្នល់ផងដែរ ដោយសារអាជីវករ ដែលលក់ទំនិញនៅក្រៅផ្សារដណ្តើមកន្លែង និងអតិថិជនរបស់អាជីវករដែលលក់ទំនិញនៅក្នុងផ្សារ។

ប្រវត្តិសង្ខេបរបស់ស្រុក៖ បវេល

- ទីតាំង៖ ស្ថិតនៅភាគខាងជើងធ្លៀងខាងលិចនៃខេត្តបាត់ដំបង
- ប្រជាជន៖ ១១៨,៥៣១(៥១% ជាស្ត្រី; ៣៧.២០% នៃប្រជាជនសរុប មានអាយុក្រោម ១៨ឆ្នាំ)
- កំណត់សម្គាល់៖ ជាតំបន់ជនបទ; គ្រួសារក្រីក្រមានចំនួន ២៦.៦០%; ៨៧% ជាកសិករ; ២២%នៃប្រជាជនបានធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេស
- ក្រុមប្រឹក្សាស្រុក៖ ១៧នាក់ (៤នាក់ជាស្ត្រី)

ដោយសារតែមានពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងអ្នកលក់ទំនិញចេះតែកើនឡើងជារៀងរាល់ថ្ងៃ សមាជិកក្រុមប្រឹក្សានៃស្រុកបវេល បានដឹងថាត្រូវតែចាត់វិធានការដោះស្រាយរឿងនេះ។ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងនេះ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ការបណ្តុះបណ្តាលសមត្ថភាព ដល់ក្រុមការងារសោភ័ណ្ឌភាពទីក្រុងរបស់ក្រុមប្រឹក្សា ក្នុងការអនុវត្តមុខងារដ៏សំខាន់មួយនេះ។

ការគាំទ្រនេះ រាប់បញ្ចូលទាំងការរៀបចំការស្ទាបស្ទង់មតិ ការរៀបចំផែនការថវិកា ការតាមដានត្រួតពិនិត្យ និងការពង្រឹងសមត្ថភាពលើការរៀបចំសេចក្តីព្រាងផែនការសកម្មភាពការងារ តាមរយៈការប្រឹក្សាយោបល់ និងកិច្ចប្រជុំជាច្រើនបន្តបន្ទាប់គ្នា។ បន្ទាប់ពីកិច្ចការសំខាន់ៗទាំងអស់ខាងលើត្រូវបាន និងរៀបចំរួចរាល់ហើយ ក្រុមប្រឹក្សា បានប្រើប្រាស់ជំនាញ និងជំនួយពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ដើម្បីរៀបចំសេចក្តីព្រាងផែនការសកម្មភាពការងារ រៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធនានា រៀបចំសេចក្តីណែនាំស្តីពីសណ្តាប់ធ្នាប់ផ្សារ និងរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹងសម្រាប់ការរៀបចំសណ្តាប់ធ្នាប់កន្លែងសាធារណៈឡើងវិញ នៅក្នុង និងនៅជុំវិញបរិវេណផ្សារ។

ជាលទ្ធផលនៃដំណើរការនេះ ក្រុមការងារសោភ័ណ្ឌភាពទីក្រុងនៃស្រុកបវេល បានពង្រឹងសណ្តាប់ធ្នាប់សាធារណៈនៅផ្សារឡើងវិញប្រកបដោយជោគជ័យ បានបង្កើតលក្ខខ័ណ្ឌសមស្រប និងសុវត្ថិភាពសម្រាប់អ្នកលក់ អ្នកទិញ និងអ្នកបើកបរ ព្រមទាំងបានកែលម្អសោភ័ណ្ឌភាពផ្សារផងដែរ។ វិធានការអនុវត្ត និងយុទ្ធសាស្ត្រទំនាក់ទំនងនៃក្រុមការងាររបស់ក្រុមប្រឹក្សា បានធ្វើឱ្យអ្នកលក់ទំនិញចំនួន ៩៥នាក់ ក្នុងចំណោម ១០០នាក់ ដែលលក់នៅតាមបណ្តោយផ្លូវជាតិ យល់ព្រមលើកតូបទំនិញរបស់ខ្លួនពីលើផ្លូវទៅលក់នៅក្នុងផ្សារវិញដោយស្ម័គ្រចិត្ត។ ជាលទ្ធផល គ្រោះថ្នាក់ចរាចរណ៍ និងការកកស្ទះចរាចរណ៍បានថយចុះ។ លើសពីនេះទៀត សំរាមសំណល់រឹងនៅក្នុង និងជុំវិញបរិវេណផ្សារ បានថយចុះយ៉ាងខ្លាំង ដោយសារការបង្កើនការយល់ដឹង និងការរៀបចំបង្កើតកន្លែងដាក់សំរាមបានត្រឹមត្រូវ ដែលកត្តានេះការពារកុំឱ្យមានគំនរសំរាមនៅកន្លែងផ្សេងទៀត និងធ្វើឱ្យមានកន្លែងចតយានយន្ត ឱ្យបានឆ្ងាយពីផ្លូវជាតិ។

ដោយមើលឃើញពីសមិទ្ធិផលទាំងនេះ ប្រធានក្រុមប្រឹក្សាស្រុក លោក ចេក ពេក បានលើកឡើង ប្រកបដោយមានមោទនភាពថា ការធ្វើឱ្យប្រសើរឡើងនូវសណ្តាប់ធ្នាប់សាធារណៈនៃផ្សារបរវេល នឹងក្លាយជាមេរៀនដ៏ល្អមួយសម្រាប់ស្រុក និងក្រុងផ្សេងៗទៀត។ ទន្ទឹមនឹងនេះដែរ លោក ឡូត សាលី អភិបាលរងស្រុកបរវេល ក៏បានបញ្ជាក់ដែរថា ការយល់ដឹងពីគុណតម្លៃនៃការសម្របសម្រួលជាបន្តបន្ទាប់ និងការរៀបចំបង្កើតបណ្តាញទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធនានានៅក្នុងផ្សារ គឺជារឿងដែលមានប្រយោជន៍ខ្លាំងណាស់ ហើយបណ្តាញនេះត្រូវតែថែរក្សាឱ្យបានល្អ។

1

រូបភាពនៅលើផ្លូវជាតិ និងនៅក្នុងផ្សារកាលពីមុន (ខាងឆ្វេង) និងបន្ទាប់ក្រុមប្រឹក្សាចេញសេចក្តីណែនាំ (ខាងស្តាំ)

2

3

4

ការដោះស្រាយបញ្ហាគ្រោះថ្នាក់ទាក់ទងនឹងអនាម័យចំណីអាហារ និងភេសជ្ជៈនៅក្នុងស្រុករតនមណ្ឌល

ការខ្វះអនាម័យរបស់អ្នកលក់ចំណីអាហារ និងភេសជ្ជៈនៅក្នុង និងជុំវិញបរិវេណសាលារៀននៅក្នុងស្រុករតនមណ្ឌល គឺជាបញ្ហាយូរយារណាស់មកហើយ ដែលកត្តានេះ ធ្វើឱ្យមាតាបិតាសិស្សបានលើកឡើងពីការព្រួយបារម្ភលើបញ្ហាសុខភាពរបស់កូនៗរបស់ពួកគេម្តងហើយម្តងទៀត។ បញ្ហានេះត្រូវបានលើកឡើងសារជាថ្មី នៅពេលមានការផ្ទុះឡើងនូវបញ្ហាក្អួតចង្អោរ រាគរុះ និងគ្រុនពោះវៀន ក្នុងចំណោមកុមារជាច្រើននៅតាមសាលារៀន ដែលបង្ក ឡើងដោយអាហារ ដែលខូច និងភេសជ្ជៈដែលមានសារធាតុពុល។ នៅពេលដែលរបាយការណ៍របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុកបានបង្ហាញពីវិសាលភាព ភាពធ្ងន់ធ្ងរ និងភាពបន្ទាន់នៃបញ្ហានេះក្រុមប្រឹក្សាស្រុករតនមណ្ឌល បានធ្វើសេចក្តីសម្រេចចិត្តលើកយកបញ្ហានេះជាអាទិភាពដំបូងបំផុត ដើម្បីចាត់វិធានការដោះស្រាយ។

ប្រវត្តិសង្ខេបរបស់ស្រុក៖ រតនមណ្ឌល

- ទីតាំង៖ ស្ថិតនៅភាគខាងត្បូងធ្លៀងខាងលិចនៃខេត្តបាត់ដំបង
- ប្រជាជន៖ ៤៥,៩១៣ (៥0% ជាស្ត្រី; ៤៤% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ
- កំណត់សម្គាល់៖ ជាតំបន់ជនបទ; គ្រួសារក្រីក្រមានចំនួន ២២.៤៩%
- ក្រុមប្រឹក្សាស្រុក៖ ១៣នាក់ (២នាក់ជាស្ត្រី)

ខណៈពេលដែលមានឆន្ទៈខ្លាំងក្នុងការដោះស្រាយបញ្ហាកង្វះអនាម័យចំណីអាហារ និងភេសជ្ជៈ ក្រុមប្រឹក្សាបានដឹងថា ខ្លួនមិនមានចំណេះដឹងពីរបៀបធ្វើការវិភាគបញ្ហាឱ្យបានត្រឹមត្រូវ និងដោះស្រាយបញ្ហាឱ្យមានប្រសិទ្ធភាពនៅឡើយទេ។ ស្របពេលជាមួយគ្នានេះដែរ សមាជិកក្រុមប្រឹក្សាបានរំឭកពីលទ្ធផលរបស់ស្រុកបាណន់ ដែលក្រុមប្រឹក្សាស្រុកនេះបានជួបប្រទះបញ្ហាស្រដៀងគ្នានឹងស្រុករតនមណ្ឌល ហើយពួកគេបានដោះស្រាយរឿងនោះ ប្រកបដោយជោគជ័យ ដោយមានការគាំទ្រពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល។ ហេតុនេះទើប ក្រុមប្រឹក្សាបានសម្រេចចិត្តស្វែងរកជំនួយពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ផងដែរ។ វគ្គប្រឹក្សាយោបល់សម្រាប់សមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាលត្រូវបានរៀបចំឡើង និងផ្តោតលើការបែងចែកតួនាទី និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា នៅក្នុងដំណើរការដោះស្រាយបញ្ហា ការប្រមូលទិន្នន័យនៅតាមសាលារៀន ការធ្វើវិភាគទិន្នន័យ និងការរៀបចំផែនការសកម្មភាពនិងថវិកា។ លើសពីនេះទៀត ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានចូលរួមចំណែកដល់ប្រសិទ្ធភាពនៃរដ្ឋបាលស្រុក ដែលឥឡូវនេះពួកគាត់អាចចេះរៀបចំសេចក្តីព្រាង និងអនុវត្តវិធានការដោះស្រាយបញ្ហា ហើយអាចបម្រើប្រជាពលរដ្ឋបានយ៉ាងត្រឹមត្រូវ។

តូបលក់អ៊ីវ៉ាន់របស់អ្នកលក់នៅក្នុងបរិវេណសាលារៀនមុនពេលអនុវត្តគម្រោង

ជាលទ្ធផល កិច្ចសហការដ៏រឹងមាំរវាងសមាជិកក្រុមប្រឹក្សា បុគ្គលិករដ្ឋបាលនៃការិយាល័យប្រតិបត្តិជាច្រើន និងនាយកសាលា ត្រូវបានរៀបចំបង្កើតឡើង។ ជាមួយគ្នានេះដែរ ស្រុកអាចរៀបចំបង្កើត និងពង្រឹងការអនុវត្តគោលការណ៍ណែនាំថ្មីចំពោះអ្នកលក់ចំណីអាហារ និងភេសជ្ជៈ ព្រមទាំងផ្តល់ជាមូលដ្ឋានគ្រឹះ សម្រាប់មន្ត្រីសុខាភិបាល និងនាយកសាលា ក្នុងការបន្តការតាមដានត្រួតពិនិត្យការប្រព្រឹត្តរបស់អ្នកលក់ចំណីអាហារចំពោះស្តង់ដារថ្មី និងការធានានូវសុវត្ថិភាពចំណីអាហារ។ លើសពីនេះទៀត យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងវេទិកាផ្សព្វផ្សាយ បានបង្រៀនសិស្សពីបុព្វហេតុដែលនាំឱ្យមានជំងឺ ដែលពួកគេធ្លាប់បានជួបប្រទះកន្លងមក និងបានជំរុញពួកគេឱ្យចេះពិនិត្យមើលកាលបរិច្ឆេទផុតកំណត់នៃចំណីអាហារដែលពួកគេនឹងទិញ។ លទ្ធផលជាវិជ្ជមានដែលបានមកពីការស្ទាបស្ទង់ ម តិលើគំនិតយោបល់របស់សិស្សានុសិស្ស មាតាបិតា និងគ្រូបង្រៀនចំពោះស្ថានភាពអនាម័យចំណីអាហារ និងភេសជ្ជៈ ដែលបានធ្វើឡើងសម្រាប់ការខិតខំនេះ គឺជាភស្តុតាងបញ្ជាក់ពីឆន្ទៈដ៏មានប្រសិទ្ធភាព របស់ក្រុមប្រឹក្សា។

ការលើកកម្ពស់ការយល់ដឹងដល់សិស្សានុសិស្ស នៅក្នុងសាលារៀន

តាមរយៈការឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ លោក ពៅ យ៉ានី សមាជិកក្រុមការងារអនាម័យ និងជាអនុប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ បានសម្តែងនូវការពេញចិត្តចំពោះសមិទ្ធផលដែលបានទទួល និងបានលើកឡើងពីជំនាញដ៏មានប្រយោជន៍នានា ដែលគាត់បានទទួលពីការងារនេះ។ ដោយរាប់ចាប់ពីសមត្ថភាពក្នុងការចាត់អាទិភាព និងរៀបចំសេចក្តីព្រាងផែនការការងារជាក់ស្តែង ដើម្បីបានទទួលស្គាល់ និងរៀបចំជាក្រុមអ្នកចូលរួម គឺជាកត្តាចាំបាច់ដើម្បីឈានទៅរកភាពជោគជ័យ។ លើសពីនេះទៀត សកម្មភាពដែលទទួលបានជោគជ័យនេះ បានបង្កើនទំនុកចិត្តរបស់ក្រុមប្រឹក្សា ដោយសារពួកគេបានមើលឃើញពីផលប៉ះពាល់ជាវិជ្ជមាន ដែលមានកើតចំពោះការរស់នៅរបស់ប្រជាពលរដ្ឋដែលពួកគេតំណាងឱ្យ។

សិស្សានុសិស្ស ដែលបានចូលរួម នៅក្នុងវេទិកាផ្សព្វផ្សាយ

ការធ្វើការរួមគ្នា ដើម្បីសុខភាពរបស់កុមារនៅក្នុងស្រុកសំឡូត

ស្រុកសំឡូត មានរឿងរ៉ាវប្រហាក់ប្រហែលគ្នានឹងបទពិសោធន៍របស់ស្រុករតនមណ្ឌលដែរ។ នៅក្នុងស្រុកនេះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ បានធ្វើការសិក្សា បន្ទាប់ពីដឹងថាមានករណីរាគរុះ និងក្អួតចង្អោរជាច្រើនកើតឡើងចំពោះសិស្សសាលា។ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ បានបង្ហាញ ពីការរកឃើញដ៏គួរឱ្យព្រួយបារម្ភថា ចំណីអាហារ និងភេសជ្ជៈគ្មានអនាម័យ ត្រូវបានលក់ស្ទើរតែនៅក្នុងគ្រប់សាលាបឋមសិក្សានៅក្នុងស្រុកនេះ។ បន្ទាប់មក ក្រុមប្រឹក្សាស្រុកបានចាប់ផ្តើមឃើញ បញ្ហានេះជាបញ្ហាអាទិភាពចំបងបំផុត។ ដោយមានឆន្ទៈក្នុងការគ្រប់គ្រងអ្នកលក់ និងចំណីអាហារ ដែលពួកគេកំពុងតែលក់ ទើបក្រុមប្រឹក្សាស្វែងរកជំនួយបច្ចេកទេស ពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល។

ប្រវត្តិសង្ខេបរបស់ស្រុក៖ សំឡូត

- ទីតាំង៖ ស្ថិតនៅភាគខាងត្បូងធៀងខាងលិចនៃខេត្តបាត់ដំបង
- ប្រជាជន៖ ៤៨,៩០៧ (៤៩% ជាស្ត្រី; ៤១% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ
- កំណត់សម្គាល់៖ ជាតំបន់ជនបទ; គ្រួសារក្រីក្រ មានចំនួន ៣១.៤០%; ៨០% ជាកសិករ
- ក្រុមប្រឹក្សាស្រុក៖ ១៣នាក់ (៤នាក់ជាស្ត្រី)

គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ដោយការរៀបចំវគ្គប្រឹក្សាយោបល់ជាបន្តបន្ទាប់ ជាមួយសមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាល លើការបែងចែកតួនាទី សមត្ថភាព និងការទទួលខុសត្រូវ របស់រដ្ឋបាលស្រុក ក៏ដូចជាការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ ការធ្វើផែនការថវិកា ការតាមដាន និងការវាយតម្លៃ។ វិធានការគាំទ្រទាំងនេះ បានបង្កើតជាមូលដ្ឋានគ្រឹះ សម្រាប់សមាជិកក្រុមប្រឹក្សា និងបុគ្គលិករដ្ឋបាល ដើម្បីទទួលបានជោគជ័យក្នុងការអនុវត្តមុខងារជាជម្រើស[៣] លើការគ្រប់គ្រងអនាម័យ និងការថែទាំសុខភាព ព្រមទាំងបានពង្រឹងសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាផងដែរ។ លើសពីនេះទៀត ការបណ្តុះបណ្តាលស្តីពីការសរសេររបាយការណ៍ និងជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពបន្ថែម ក៏ត្រូវបានផ្តល់ជូនផងដែរ។

ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ សមាជិកក្រុមប្រឹក្សា គណៈអភិបាល រដ្ឋបាលស្រុក និងបុគ្គលិក ការិយាល័យអប់រំ បានធ្វើការស្រាវជ្រាវ និងរៀបចំបង្កើតក្របខ័ណ្ឌច្បាប់ ដើម្បីធ្វើការណែនាំពីបទដ្ឋានអនាម័យ កាលបរិច្ឆេទផុតកំណត់ និងការត្រួតពិនិត្យចំពោះអ្នកលក់ទំនិញជាប្រចាំ។ ទន្ទឹមនឹងនេះដែរ គ្រូបង្រៀន និងសិស្សានុសិស្ស ក៏ត្រូវបានបង្រៀនឱ្យចេះអានកាលបរិច្ឆេទផុតកំណត់នៃទំនិញ និងរបៀបឱ្យអ្នកលក់មានគណនេយ្យភាពក្នុងការលក់ចំណីអាហារស្រស់ៗ។ ក្នុងដំណាក់កាលនេះ មន្ត្រីអធិការកិច្ចផ្នែកសុខភាព មកកាំកុងត្រូល បានធ្វើបង្ហាញពីរបៀបមើល

សមាជិកក្រុមប្រឹក្សា ធ្វើអធិការកិច្ចតួបលក់ទំនិញ និងបង្រៀនសិស្សានុសិស្ស និងគ្រូបង្រៀនពីរបៀបពិនិត្យមើលចំណីអាហារ និងភេសជ្ជៈដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព ដោយ មានការគាំទ្រពីមន្ត្រីអធិការកិច្ចផ្នែកសុខភាពមកពីកាំកុងត្រូល

៣. មុខងារជាជម្រើស សំដៅដល់មុខងារប្រតិបត្តិរបស់ក្រសួង ស្ថាប័ន ដែលរដ្ឋបាលថ្នាក់ក្រោមជាតិអាចជ្រើសរើសយកមកអនុវត្តបាន។ ដើម្បីអាចបំពេញលក្ខខណ្ឌនេះបាន មុខងារទាំងនេះត្រូវតែជាមុខងារដែលមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ឬ អាចជាមុខងារដែលកំពុងត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន ប៉ុន្តែក្រសួង ស្ថាប័នទាំងនោះពុំជំទាស់ចំពោះក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើសមុខងារទាំងនោះយកមកអនុវត្ត។ មុខងារដែលបំពេញតាមលក្ខខណ្ឌថាជាមុខងារជាជម្រើស ត្រូវបានកំណត់ដោយច្បាប់។

សិស្សកំពុងចែករំលែកមេរៀនបទពិសោធន៍ស្តីពីសុវត្ថិភាព និងអសុវត្ថិភាពចំណីអាហារជាមួយសិស្សានុសិស្ស ដទៃទៀត គ្រូបង្រៀន និងមាតាបិតាសិស្សនៅក្នុងវេទិការផ្សព្វផ្សាយ

ចំណីអាហារ និងភេសជ្ជៈ ដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព ព្រមទាំងបានផ្តល់នូវឧទាហរណ៍ និងការក្រើនរំឭកឱ្យប្រយ័ត្នប្រយែង ចំពោះចំណីអាហារ ជាច្រើនករណី។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំឱ្យថយចុះ នូវករណីពុលចំណីអាហារ ដែលកត្តានេះអាចមានការទាក់ទងទៅនឹងអ្នកលក់នៅក្នុង និងជុំវិញបរិវេណសាលារៀន។

យោងតាមលទ្ធផលនេះ លោក កុល បុត្រ ប្រធានក្រុមប្រឹក្សាស្រុក បានសម្តែងពីការពេញចិត្តរបស់លោកថា ចំណេះដឹងដែលទទួលបានពីការអនុវត្តគម្រោងនេះ ពិតជាបានជួយក្រុមប្រឹក្សាឱ្យចេះធ្វើការគ្រប់គ្រងគម្រោង និងមានសមត្ថភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តកាន់តែប្រសើរជាងមុន។លោកបានបន្ថែមថាការអនុវត្តល្អដែលបានរៀនសូត្រកន្លងមកនេះ នឹងជួយនាំឱ្យមានការអនុវត្តមុខងារជាជម្រើសបន្ថែមទៀត និងធ្វើជាគំរូដល់ស្រុកផ្សេងទៀតផងដែរ។ ចុងក្រោយ គាត់បានលើកទឹកចិត្តដល់សមាជិកសមាជិកាក្រុមប្រឹក្សាស្រុកសំឡូត រដ្ឋបាលមូលដ្ឋាន និងការិយាល័យជំនាញនានា ឱ្យរក្សានូវបរិយាកាសសម្រាប់កិច្ចសហការដ៏ល្អនេះ។

សិស្សកំពុងអានគោលការណ៍ណែនាំស្តីពីសុវត្ថិភាពចំណីអាហារ

ការលើកកម្ពស់គុណភាពការងារ និងប្រសិទ្ធភាពនៃការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយនៅក្រុងបាត់ដំបង

ប្រវត្តិសង្ខេបរបស់ក្រុង៖ បាត់ដំបង

- ទីតាំង៖ ស្ថិតនៅចំស្នូលនៃខេត្តបាត់ដំបង
- ប្រជាជន៖ ១៦១,០៧២ (៥០% ជាស្ត្រី; ៣៤% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ)
- កំណត់សម្គាល់៖ ជាតំបន់ជនបទនិងទីប្រជុំជន; គ្រួសារក្រីក្រមានចំនួន ២២.៨៣%; ៧១.៣០% នៃប្រជាជនធ្វើការនៅក្នុងវិស័យសេវា
- ក្រុមប្រឹក្សាស្រុក៖ ១៥នាក់ (៣នាក់ជាស្ត្រី)

ក្នុងក្រុងបាត់ដំបង ប្រជាពលរដ្ឋបានតវ៉ាអំពីការផ្តល់សេវាដែលមិនទាន់បានពេញលេញនៅការិយាល័យច្រកចេញចូលតែមួយ ដោយលើកឡើងថាមន្ត្រីមិនទាន់ទទួលបានការបណ្តុះបណ្តាលបានគ្រប់គ្រាន់ នៅពុំទាន់អាចផ្តល់ព័ត៌មានបានគ្រប់ជ្រុងជ្រោយ ឬ មិនបានជួយរៀបចំឯកសារសំណើសុំ។ ដោយបានដឹងពីភាពមិនសូវពេញចិត្តរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សាក្រុងបានធ្វើសេចក្តីសម្រេចជ្រើសរើសការកែលម្អការផ្តល់សេវារដ្ឋបាល ជាកិច្ចការដ៏មានអាទិភាពមួយ។ ដោយមានបំណងស្វែងយល់អំពីឫសគល់នៃបញ្ហា និងចង់ដោះស្រាយបញ្ហា ដោយមានផែនការច្បាស់លាស់ទើបក្រុមប្រឹក្សាក្រុងបានស្វែងរកការគាំទ្រផ្នែកបច្ចេកទេស ពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល។

គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលបានជួយគាំទ្រតាមវិធីសាស្ត្រ និងដំណាក់កាលជាបន្តបន្ទាប់។ ដំបូង គម្រោងនេះបានជួយរៀបចំបង្កើតក្រុមការងារមួយដែលមានសមាជិកក្រុមប្រឹក្សា បុគ្គលិករដ្ឋបាលក្រុង និងគណៈអភិបាល។ ក្រុមការងារនេះមានតួនាទីសំខាន់ក្នុងការសិក្សាស្វែងយល់ពីបញ្ហានេះឲ្យបានគ្រប់ជ្រុងជ្រោយ រៀបចំវិធានការលម្អិត និងធ្វើសកម្មភាពដោះស្រាយតាមរបៀបសម្របសម្រួលដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង។ ទីពីរ ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានរបស់គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ប្រឹក្សាយោបល់ដល់អ្នកពាក់ព័ន្ធនានា នៅក្នុងការរៀបចំផែនការសកម្មភាព និងរបាយការណ៍តាមដាន ដែលអនុញ្ញាតឱ្យមានវិធីសាស្ត្រណែនាំ និងការកែតម្រូវនាពេលអនាគត។ ទីបី គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីស្តីពីការផ្តល់សេវាប្រកបដោយសីលធម៌ ដើម្បីដោះស្រាយបញ្ហាភ្ជាប់ភ្ជាក់ររបស់ប្រជាពលរដ្ឋ ដែលបានលើកឡើងអំពីការផ្តល់សេវាដែលមិនទាន់បានពេញលេញ។ ទីបួន គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ធ្វើយុទ្ធនាផ្សព្វផ្សាយ រៀបចំវេទិកាពិភាក្សាដេញដោលជាលក្ខណៈបើកចំហជាមួយសហគមន៍អំពីសេវាសាធារណៈ និងអំពីការិយាល័យប្រជាពលរដ្ឋ[4] និងយន្តការដោះស្រាយបណ្តឹងតវ៉ា ដែលមានក្នុងការិយាល័យច្រកចេញចូលតែមួយ។ ស្របពេលជាមួយគ្នានេះដែរ ការិយាល័យ

តំណាងក្រសួងមហាផ្ទៃ រដ្ឋបាលក្រុង និងគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានជួបដើម្បីពិភាក្សាពីការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងគុណភាព

(៤). ការិយាល័យប្រជាពលរដ្ឋ គឺជាយន្តការអព្យាក្រឹត្យមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការទទួល សម្របសម្រួល និងដោះស្រាយបណ្តឹងតវ៉ាខាងផ្នែករដ្ឋបាល ពីប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងក្រមសីលធម៌របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។ ការិយាល័យប្រជាពលរដ្ឋ តំណាងឯករាជ្យ និងមិនប្រកាន់បក្សពួក ដែលមានសិទ្ធិអំណាចក្នុងការអង្កេត រាយការណ៍ និងផ្តល់អនុសាសន៍ចំពោះករណីបណ្តឹងតវ៉ា និងនីតិវិធីរដ្ឋបាល។ គាត់មិនមែនជាចៅក្រម ឬតុលាការកាត់ក្តីទេ ហើយគាត់មិនមានសិទ្ធិអំណាចចេញបទបញ្ជា ឬចាត់វិធានការខាងផ្នែករដ្ឋបាលនោះដែរ។

បុគ្គលិកកំពុងចែករំលែកពីទស្សនៈស្តីពីការគ្រប់គ្រងគុណផលបែបថ្មី និងប្រព័ន្ធយន្តការដាក់ពាក្យបណ្តឹងឱ្យគ្នាទៅវិញទៅមក

ច្រកចេញចូលតែមួយរបស់ក្រុងបាត់ដំបង ត្រូវបានជ្រើសរើសដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងគុណផលដែលរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការគាំទ្របច្ចេកទេសពីគម្រោងមុននៃគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល។ ប្រព័ន្ធគ្រប់គ្រងគុណផលមានគោលបំណងបង្កើនគុណផលការងាររបស់មន្ត្រីរាជការស៊ីវិល តាមរយៈការគ្រប់គ្រងធនធាន ដែលមានរចនាសម្ព័ន្ធត្រឹមត្រូវ។ ដោយមានកាលវិភាគប្តូរវេនធ្វើការ គុណផលការងារ និងយន្តការត្រួតពិនិត្យគុណភាព ក៏ដូចជា យន្តការផ្តល់យោបល់ត្រឡប់ ត្រូវបានបង្កើតឡើងយ៉ាងល្អផងដែរ។ ជាមួយនឹងការកើនឡើងនូវគុណផលការងាររបស់មន្ត្រី បញ្ហាអសកម្មមួយចំនួនក្នុងការផ្តល់សេវាត្រូវបានរកឃើញ និងកែលម្អផងដែរ។

ប្រធានការិយាល័យច្រកចេញចូលតែមួយកំពុងផ្ទៀងផ្ទាត់ឯកសារ និងពិនិត្យសុពលភាពឯកសាររបស់ប្រជាពលរដ្ឋ

បន្ទាប់មកភាពប្រសើរឡើងដ៏គួរអោយកត់សម្គាល់នៅក្នុងគុណភាពនៃការបំពេញមុខងារ និងប្រសិទ្ធភាពនៃការផ្តល់សេវា ត្រូវបានធ្វើការវាស់វែង។ បន្ទាប់ពីបានផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងពីសេវា ដែលបានកែលម្អនាពេលកន្លងមក បណ្តឹងតវ៉ាអំពីគុណភាពសេវាពីប្រជាពលរដ្ឋក៏បានថយចុះដែរ។ ការស្ទាបស្ទង់មតិមួយដែលបានធ្វើជាមួយអ្នកចូលរួមចំនួន១៣២នាក់ ដែលមកពីភូមិចំនួន ២០ភូមិនៅក្នុងក្រុងបាត់ដំបង កាលពីថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ បានបង្ហាញឲ្យឃើញថា អ្នកចូលរួមចំនួន ៩៥% បានយល់ថា គុណភាពនៃការផ្តល់សេវាមានភាពប្រសើរឡើង ហើយបានបង្ហាញនូវការជឿទុកចិត្តកាន់តែច្រើនមកលើការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។

ភាពប្រសើរឡើង នៃគុណផលការងាររបស់បុគ្គលិកធ្វើឱ្យការផ្តល់សេវាកាន់តែប្រសើរ នៅក្នុងស្រុកមោងឫស្សី

ស្រុកមោងឫស្សី បានជួបប្រទះបញ្ហាប្រឈមស្រដៀងគ្នានឹងក្រុងបាត់ដំបងដែរ។ នៅក្នុងករណីនេះ ទាំងប្រជាពលរដ្ឋ និងទាំងបុគ្គលិកបម្រើការនៅក្នុងការិយាល័យច្រកចេញចូលតែមួយ បានត្អូញត្អែរពីស្ថានភាពទូទៅមិនល្អនៅក្នុងការិយាល័យច្រកចេញចូលតែមួយ។ នៅពេលការិយាល័យច្រកចេញចូលតែមួយបានចាប់ផ្តើមធ្វើប្រតិបត្តិការក្នុងស្រុកមោងឫស្សីកាលពីដើមឆ្នាំ ២០១៧ ការិយាល័យនេះមិនមានផែនការត្រឹមត្រូវពីរបៀប ដែលការិយាល័យនេះត្រូវផ្តល់សេវា ឬកិច្ចការអ្វីខ្លះដែលការិយាល័យនេះគួរតែធ្វើឱ្យសម្រេចក្នុងរយៈពេលវែងនោះទេ។ ការិយាល័យនេះក៏មិនមានការរៀបចំការពិពណ៌នាការងារអំពីតួនាទី និងការទទួលខុសត្រូវច្បាស់លាស់សម្រាប់បុគ្គលិកម្នាក់ៗផងដែរ។

ប្រវត្តិសង្ខេបរបស់ស្រុក៖ មោងឫស្សី

- ទីតាំង៖ ស្ថិតនៅប៉ែកអាគ្នេយ៍នៃខេត្តបាត់ដំបង
- ប្រជាជន៖ ១៣០,៣៣៧ (៥០% ជាស្ត្រី; ៤០% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ)
- កំណត់សម្គាល់៖ ជាតំបន់ជនបទនិងទីប្រជុំជន; គ្រួសារក្រីក្រមានចំនួន ២៦.៥៥%; ២/៣ នៃប្រជាជនពេញវ័យជាកសិករ
- ក្រុមប្រឹក្សាស្រុក៖ ១៥នាក់ (៣នាក់ជាស្ត្រី)

បុគ្គលិកធ្វើការត្រួតគ្នាហើយការបែងចែកការងារសម្រាប់បុគ្គលិកម្នាក់ៗមិនស្មើគ្នាទៀត។ ប្រជាពលរដ្ឋត្អូញត្អែរអំពីគុណភាពសេវា ហើយមន្ត្រីបម្រើការងារនៅក្នុងការិយាល័យច្រកចេញចូលតែមួយមិនទាន់បានយល់ដឹងច្បាស់អំពីរបៀបរបបធ្វើការងារ។ លើសពីនេះទៅទៀត នីតិវិធីស្នើសុំសេវា ពេលខ្លះនៅមានភាពមិនច្បាស់លាស់ ឬស្មុគ្រស្មាញពេក ដែលធ្វើឱ្យប្រជាពលរដ្ឋពិបាកយល់។ ចំណែកឯ ប្រជាពលរដ្ឋភាគច្រើនមិនបានដឹងថា មានការិយាល័យច្រកចេញចូលតែមួយនៅក្នុងស្រុកនេះនោះទេ។ ហេតុនេះ ក្រុមប្រឹក្សាស្រុក និងប្រធានការិយាល័យច្រកចេញចូលតែមួយ បានសម្រេចចិត្តស្វែងរកជំនួយបច្ចេទេសពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការនិងរដ្ឋបាល។ ដោយសារការិយាល័យច្រកចេញចូលតែមួយ នៅក្នុងស្រុកមោងឫស្សី ត្រូវបានជ្រើសរើសដាក់ឱ្យអនុវត្តសាកល្បងនូវប្រព័ន្ធគ្រប់គ្រងគុណផលដែលរៀបចំដោយក្រសួងមុខងារសាធារណៈ ហេតុនេះទើបគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលផ្តល់ការគាំទ្រចំពោះការដាក់ឱ្យដំណើរការការិយាល័យច្រកចេញចូលតែមួយថ្មីនេះ ក្នុងរូបភាព២យ៉ាង រួមមាន៖ ទី១ គឺគាំទ្រយុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីសេវា ដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ ដល់ប្រជាពលរដ្ឋ ដែលរៀបចំឡើងដោយរដ្ឋបាលស្រុក និងទី២ គឺការផ្តល់

កិច្ចប្រជុំត្រួតពិនិត្យគុណផលឡើងវិញរវាងមន្ត្រី និងប្រធានការិយាល័យច្រកចេញចូលតែមួយ

មន្ត្រីការិយាល័យច្រកចេញចូលតែមួយ កំពុងរៀបចំឯកសារសំណើសុំសេវាពីប្រជាពលរដ្ឋ

ការបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រងគុណផលជាបន្តបន្ទាប់ ដល់អភិបាលរងទទួលបន្ទុកការិយាល័យច្រកចេញចូលតែមួយ នាយករដ្ឋបាល ប្រធាន និងអនុប្រធានការិយាល័យច្រកចេញចូលតែមួយ ព្រមទាំងមន្ត្រីផ្នែកជួរមុខនិងផ្នែកជួរក្រោយមួយចំនួនផងដែរ។ ការបណ្តុះបណ្តាលនេះបានផ្តោតសំខាន់លើការរៀបចំផែនការការងារប្រចាំឆ្នាំ ការរៀបចំការពិពណ៌នាមុខតំណែង និងការរៀបចំលក្ខខណ្ឌការងារដោយផ្អែកតាមអនុសាសន៍របស់ក្រសួងមុខងារសាធារណៈ។ តាមរយៈសមាសធាតុទាំងនេះ វាបានជួយកំណត់គោលបំណង តួនាទី និងការតម្រង់ទិសសម្រាប់បុគ្គលិកបានច្បាស់លាស់។

អ្នកបើកបរកំពុងបំពាក់ស្លាកលេខថ្មីដែលទើបទទួលបានពីការិយាល័យច្រកចេញចូលតែមួយ ក្នុងរយៈពេល២ម៉ោង

វគ្គបណ្តុះបណ្តាល និងការប្រឹក្សាយោបល់បានធ្វើឱ្យភាគីពាក់ព័ន្ធនានា អាចរៀបចំផែនការការងារប្រចាំឆ្នាំឆ្លើយតបនឹងគោលដៅដែលចង់សម្រេច កំណត់តួនាទីបានច្បាស់លាស់សម្រាប់បុគ្គលិកទាំងអស់ និងបង្កើតឱ្យមានរចនាសម្ព័ន្ធច្បាស់លាស់តាមរយៈលក្ខខណ្ឌការងារ។ ហេតុនេះ តាមរយៈការមានប្រព័ន្ធគ្រប់គ្រងល្អ ការត្រួតពិនិត្យមើលគុណផលរបស់មន្ត្រីឡើងវិញ និងការគ្រប់គ្រងគុណផលរបស់មន្ត្រី ត្រូវបានដាក់ឱ្យអនុវត្ត។ ក្នុងកម្រិតបុគ្គលសមាជិកក្រុមប្រឹក្សាអាចមានសមត្ថភាពរៀបចំរបាយការណ៍វឌ្ឍនភាពដែលឆ្លើយតបនឹងគោលដៅជាប្រចាំបានដោយឯករាជ្យ។

កត្តាជោគជ័យនៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ គឺបុគ្គលិកគ្រប់រូបបានយល់ច្បាស់ពីតួនាទីរបស់ខ្លួន ដែលកត្តានេះនាំឱ្យមានការបែងចែកកិច្ចការ និងអាចឈានទៅដល់ការផ្តល់សេវាជូនដល់ប្រជាពលរដ្ឋបានទាន់ពេលវេលា។ លើសពីនេះទៀត បុគ្គលិកបានបង្ហាញពីទំនាក់ទំនងល្អប្រសើររវាងបុគ្គលិក និងអ្នកគ្រប់គ្រងផងដែរ។ ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នានេះ ការិយាល័យប្រជាពលរដ្ឋនៃស្រុកមោងឫស្សីបានផ្តល់ព័ត៌មានត្រឡប់ជាវិជ្ជមានលើគុណភាពនៃការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ។ តាមរយៈការស្ទាបស្ទង់មតិជាមួយអតិថិជនចំនួន២១០នាក់មាន ៩៧.១៤%បានឆ្លើយថាបុគ្គលិករបស់ការិយាល័យច្រកចេញចូលតែមួយធ្វើការមានប្រសិទ្ធភាព និងរហ័សទាន់ចិត្ត ៧៧.១៤% យល់ថា នីតិវិធីសម្រាប់ស្នើសុំសេវាមានភាពងាយស្រួល ចំណែក ៩៩.៥២% បានបង្ហាញពីការពេញចិត្តជាទូទៅចំពោះការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ។ ប្រជាពលរដ្ឋទូទៅក៏បានបង្ហាញពីការពេញចិត្តកាន់តែខ្លាំង ចំពោះការិយាល័យច្រកចេញចូលតែមួយផងដែរ។ លោកស្រី ម៉ា លី ប្រជាពលរដ្ឋរស់នៅក្នុងស្រុកមោងឫស្សីបានរៀបរាប់ប្រាប់ថា បុគ្គលិកធ្វើការនៅទីនេះមានភាពរាក់ទាក់ ទម្រង់បែបបទមានភាពងាយស្រួល និងការផ្តល់សេវា គឺលឿន ខ្ញុំពេញចិត្តចំពោះការផ្តល់សេវានេះ។ ដោយសារតែមានការលើកកម្ពស់ការយល់ដឹងទាក់ទង នឹងការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ ទើបមានការមកទទួលយកសេវាពីការិយាល័យច្រកចេញចូលតែមួយមានច្រើនផ្សេងៗគ្នា។ នៅក្នុងឆ្នាំ ២០១៧ សេវាសម្រាប់ការធ្វើនីត្យានុកូលកម្ម ការចុះអត្រានុកូលដ្ឋាន និងការសុំស្លាកលេខមានច្រើនលើសលុប បើធៀបនឹងការស្នើសុំលើសេវាដទៃទៀត។ ដោយឡែក នៅក្នុងឆ្នាំ ២០១៨ សេវាខាងលើនៅតែមានចំនួនលើសលុបដដែល ប៉ុន្តែចំនួនស្នើសុំអាជ្ញាប័ណ្ណអាជីវកម្ម ការស្នើសុំការសាងសង់ និងការងារកសិកម្ម មានការកើនឡើងទ្វេរដង និងក្នុងករណីខ្លះទៀត បានកើនឡើងដល់ទៅ ៤ដង។ ចំនួនសេវាសរុបដែលបានផ្តល់ បានកើនឡើងពី ១៦,៥៤៩ នៅក្នុងឆ្នាំ២០១៧ ដល់ ១៩,០៧៦ ក្នុងឆ្នាំ២០១៨។

ការិយាល័យច្រកចេញចូលតែមួយ ក៏បានធ្វើការស្ទង់មតិតាមឈ្មោះគ្រួសារនៅក្នុងស្រុកផងដែរ។ នៅក្នុងការស្ទាបស្ទង់មតិប្រមូលទិន្នន័យដើមគ្រា និងការវាយតម្លៃក្នុង ៦០គ្រួសារក្នុងស្រុកគ្រួសារដែលបានឮពីការិយាល័យច្រកចេញចូលតែមួយបានកើនឡើងពី ២៥% ទៅ ៩៧%។ ៨២% គ្រួសារបានដឹងពីប្រភេទសេវាដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ ហើយការប្រើប្រាស់សេវាទាំងនេះបានកើនពី ១២% ទៅ ៤៥%។

ការដោះស្រាយបញ្ហាសំរាម សំណល់រឹង ដើម្បីជួយលើកកម្ពស់សក្តានុពលទេសចរណ៍របស់ស្រុកបាណន់

ប្រវត្តិសង្ខេបរបស់ស្រុក៖ បាណន់

- ទីតាំង៖ ស្ថិតនៅចំកណ្តាលនៃខេត្តបាត់ដំបង
- ប្រជាជន៖ ១០៧,៤៥៣ (៤៩% ជាស្ត្រី; ៣៦.៨០% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ)
- កំណត់សម្គាល់៖ ជាតំបន់ជនបទ; គ្រួសារក្រីក្រមានចំនួន ១៤.៤០%; ២/៣ នៃប្រជាជន ជាអ្នកធ្វើចំការ
- ក្រុមប្រឹក្សាស្រុក៖ ១៧នាក់ (២នាក់ជាស្ត្រី)

បាណន់ គឺជាស្រុកដែលមានសក្តានុពលខាងវិស័យទេសចរណ៍ខ្លាំង។ ប៉ុន្តែបញ្ហាសំរាម សំណល់រឹងដែលនៅរាយប៉ាយនៅកន្លែងសំខាន់ៗ បានធ្វើឱ្យសក្តានុពលនេះធ្លាក់ចុះ ដោយសារវាបានធ្វើឱ្យខូចសោភ័ណ្ឌភាពស្រុក និងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាជន និងអ្នកទេសចរ។ បញ្ហាសំរាម សំណល់រឹងនេះ គឺជាប្រធានបទមួយក្នុងប្រធានបទចំនួន ១០ ដែលបានលើកឡើងដោយប្រជាពលរដ្ឋនៅក្នុងវេទិកាពិគ្រោះយោបល់ហេតុនេះទើបក្រុមប្រឹក្សាស្រុកបាណន់បានសម្រេចចិត្តជ្រើសយកបញ្ហានេះជាការងារអាទិភាពចំបងដើម្បីដោះស្រាយ។ ដើម្បីសិក្សាពីឫសគល់នៃបញ្ហា និងសិក្សាពីរបៀបដោះស្រាយបញ្ហានេះ ក្រុមប្រឹក្សាបានសម្រេចចិត្ត ស្វែងរកជំនួយបច្ចេកទេសពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល។

ជាការឆ្លើយតប គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស តាមរយៈវគ្គប្រឹក្សាយោបល់ដើម្បីកំណត់ពីមូលហេតុ និងយន្តការនានាដែលនាំឱ្យមានគំនរសំរាម។ ជាលម្អិត ការប្រឹក្សាយោបល់លើការប្រមូលព័ត៌មាន ការតាមដានត្រួតពិនិត្យ និងការវិភាគឧបករណ៍នានា ត្រូវបានរៀបចំឡើង ដើម្បីផ្តល់សិទ្ធិអំណាចដល់សមាជិកក្រុមប្រឹក្សាក្នុងដំណើការនៃការវាយតម្លៃ និងដំណោះស្រាយបញ្ហា។ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ក៏បានជួយក្រុមប្រឹក្សាក្នុងការរៀបចំគម្រោងសំណើសុំ និងផ្តល់យោបល់លើការអនុវត្តផែនការសកម្មភាពការងារផងដែរ។ លើសពីនេះទៀត គម្រោងនេះក៏បានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដើម្បីជួយក្រុមប្រឹក្សាក្នុងការអនុវត្តកិច្ចការនេះផងដែរ។ កិច្ចខិតខំប្រឹងប្រែងទាំងនេះ បាននាំឱ្យក្រុមប្រឹក្សាអាចវាយតម្លៃបញ្ហាប្រឈមបានលឿនមុនពេល រៀបចំសេចក្តីផែនការសកម្មភាពដោយអមជាមួយវិធានការជាក់លាក់ និងបានចាត់ចែងមូលនិធិសម្រាប់ដោះស្រាយបញ្ហាសំរាម សំណល់រឹងនេះ។

ប្រជាពលរដ្ឋកំពុងចូលរួមក្នុងដំណើរការប្រមូលព័ត៌មាន

ជាលទ្ធផល ក្រុមប្រឹក្សាបានសម្រេចយកបញ្ហាដែលទាក់ទងនឹងអាកប្បកិរិយា ហើយបានចាប់ផ្តើមយុទ្ធនាការលើកកម្ពស់ការយល់ដឹងនៅទូទាំងស្រុក និងនៅវេទិកាពិគ្រោះយោបល់ក្នុងគោលបំណងបង្កើនការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីផលប៉ះពាល់អវិជ្ជមានរបស់សំរាម សំណល់រឹង លើសពីនេះទៀត យុទ្ធនាការសម្អាតក្នុងស្រុកត្រូវ

សមាជិកក្រុមប្រឹក្សាគណៈអភិបាល គ្រូបង្រៀន សិស្សានុសិស្ស មន្ត្រីនគរបាល និងប្រជាពលរដ្ឋ កំពុងចូលរួមនៅក្នុងយុទ្ធនាការបោសសម្អាតស្រុក

បានរៀបចំឡើងផងដែរដែលមានអ្នកពាក់ព័ន្ធជាច្រើនចូលរួមរួមមានសមាជិកក្រុមប្រឹក្សាស្រុកគណៈអភិបាល បុគ្គលិកក្រុមប្រឹក្សា មន្ត្រីនគរបាល សិស្សានុសិស្ស និងប្រជាពលរដ្ឋ បានចូលរួមដើរវើសសំរាម សំណល់រឹងនៅតាមដងផ្លូវ។

លើសពីនេះទៀត ក្រុមការងាររបស់ស្រុក ដែលត្រូវបានរៀបចំបង្កើតឡើងដើម្បីដោះស្រាយបញ្ហាប្រឈមនេះ ក៏បានដាក់ដំឡើងផ្ទាំងប៉ាណូខ្នាតធំនៅតាមដងផ្លូវ និងតំបន់ទីក្រុងផងដែរ ក្នុងគោលបំណងដើម្បីពន្យល់ និងធានាឱ្យមានការចោលសំរាម សំណល់រឹងឱ្យបានត្រឹមត្រូវ។ ធុងដាក់សំរាម ត្រូវបានបញ្ជូនទៅឱ្យអ្នកពាក់ព័ន្ធ និងទីកន្លែងដែលត្រូវបានជ្រើសរើស ដើម្បីលុបបំបាត់ការកើនឡើងនូវសំរាម សំណល់រឹងផងដែរ។ ក្នុងអំឡុងពេលវេទិកាផ្សព្វផ្សាយអ្នកលក់ទំនិញនៅក្នុងផ្សារ បានសម្តែងការដឹងគុណចំពោះការយកចិត្តទុកដាក់សម្អាតជុំវិញបរិវេណផ្សារ ហើយបានលើកឡើងពីផលប៉ះពាល់វិជ្ជមានចំពោះដំណើរការក្នុងផ្សារ និងលំហូររបស់អតិថិជន។

ដោយឆ្លើយតបទៅនឹងឫសគល់នៃមូលហេតុផ្សេងទៀតទាក់ទងនឹងក្រុមហ៊ុនប្រមូលសំរាមដែលមិនបានគោរពកិច្ចសន្យា និងប្រមូលសំរាមមិនទៀងទាត់ ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ បានសម្រេចស្វែងរកភ្នាក់ងារប្រមូលសំរាម សំណល់រឹងដទៃទៀត។ ឃុំមួយចំនួនបានបង្កើតភាពជាដៃគូបណ្តោះអាសន្នជាមួយក្រុមហ៊ុនប្រមូលសំរាមឯកជនតូចៗ ដើម្បីដោះស្រាយបញ្ហា ខណៈពេលដែលកំពុងរកដំណោះស្រាយសម្រាប់រយៈពេលវែងសម្រាប់ឃុំទាំងអស់នៅស្រុក។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ស្រុកក្នុងការគ្រប់គ្រងអនាម័យសាធារណៈប្រកបដោយប្រសិទ្ធភាពបានធ្វើស្រុកមានភាពទាក់ទាញជាងមុន ហេតុនេះសក្តានុពល ក្នុងការទាក់ទាញទេសចរណ៍កាន់តែមានភាពប្រសើរឡើង។

ក្រុមការងារ និងតំណាង GIZ បានផ្តល់ធុងសំរាមដល់អ្នកពាក់ព័ន្ធ

ការដោះស្រាយបញ្ហាផ្ទៃក្នុង និងពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាស្រុកថ្មគោលរបស់ខ្លួន

ប្រវត្តិសង្ខេបរបស់ស្រុក៖ ថ្មគោល

- ទីតាំង៖ ស្ថិតនៅភាគខាងជើងនៃខេត្តបាត់ដំបង
- ប្រជាជន៖ ១៣៩,៨១៦ (៥១% ជាស្ត្រី; ៣៩% នៃប្រជាជនសរុប មានអាយុក្រោម១៨ឆ្នាំ)
- កំណត់សម្គាល់៖ ជាតំបន់ជនបទ; គ្រួសារក្រីក្រ មានចំនួន ២៥.៦៦%; ៧៦.៩០%; នៃប្រជាជនជាកសិករ
- ក្រុមប្រឹក្សាស្រុក៖ ២១នាក់ (៣នាក់ជាស្ត្រី)

ក្រុមប្រឹក្សាស្រុកថ្មគោលធ្លាប់បានជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា៖ សមាជិកក្រុមប្រឹក្សាស្រុកពុំទាន់បានយល់ច្បាស់អំពីតួនាទី ភារកិច្ចនិងសិទ្ធិអំណាចរបស់ខ្លួន វប្បធម៌នៃការជជែកដែកដៃ ក្នុងចំណោមសមាជិកក្រុមប្រឹក្សាពុំសូវឃើញមាន ហើយការប្រាស្រ័យទាក់ទងរវាងក្រុមប្រឹក្សាស្រុកជាមួយគណៈអភិបាលនិងរដ្ឋបាលកើតមានតិចតួចនៅឡើយ។ ជារួម ក្រុមប្រឹក្សាស្រុកមិនសូវបានបំពេញតួនាទីភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនពេញលេញនៅឡើយ។ ដោយបានយល់អំពីស្ថានភាព រួមជាមួយនឹងឆន្ទៈក្នុងការកែលម្អ ទើបសមាជិកក្រុមប្រឹក្សាស្រុកបានសម្រេចចិត្តស្វែងរកការគាំទ្រពីគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ដែលជាដៃគូរបស់ខ្លួន។

ឆ្លើយតបទៅនឹងសំណូមពរនេះ គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ក៏បានរៀបចំវគ្គឆ្លុះបញ្ចាំងមួយ ដើម្បីកំណត់បាននូវអ្វីដែលជាចំណុចខ្លាំង និងចំណុចខ្វះខាត ក៏ដូចជាកត្តាប្រឈមនានា ពិសេសអំឡុងពេលដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ នៅក្នុងវគ្គឆ្លុះបញ្ចាំងនេះ ដំណើរការកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ព្រមទាំងតួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សា និងគណៈអភិបាលដែលមានចែងក្នុងច្បាប់ ត្រូវបានវិភាគ។

នៅពេលដែលបញ្ហាចំបងៗត្រូវបានកំណត់រួមគ្នារួចរាល់ហើយ ទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋានរបស់គម្រោង បានរៀបចំទស្សនទាន ដើម្បីពង្រឹងសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធសំខាន់ៗមកពីស្ថាប័នផ្សេងទៀតក្នុងស្រុក។ គម្រោងបានផ្តល់ជាវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ដោយផ្តោតលើតួនាទី និងការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សានិងគណៈអភិបាលវិធីសាស្ត្រនៃការកំណត់និងចាត់អាទិភាពបញ្ហាដែលសហគមន៍ជួបប្រទះ ព្រមទាំងពីរបៀបរៀបចំបង្កើតក្រុមការងារដើម្បីដោះស្រាយបញ្ហា។ លើសពីនេះទៀតវគ្គបណ្តុះបណ្តាលបានបង្ហាត់បង្ហាញដល់ក្រុមប្រឹក្សា និងអ្នកពាក់ព័ន្ធអំពីការរៀបចំផែនការសកម្មភាពការងារ កម្រងសំណួរ សំណើគម្រោង និងរបាយការណ៍។

សមាជិកក្រុមប្រឹក្សាកំពុងចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីតួនាទីរបស់ក្រុមប្រឹក្សា

ក្រុមការងាររបស់ក្រុមប្រឹក្សាស្រុកចូលរួមកំណត់បញ្ហា

ទន្ទឹមនឹងការពង្រឹងសមត្ថភាពរបស់ក្រុមប្រឹក្សា និងមន្ត្រីដទៃទៀត ការបណ្តុះបណ្តាលក៏បានជួយពួកគាត់ឲ្យចេះស្តាប់ប្រកបដោយប្រសិទ្ធភាព និងកំណត់តម្រូវការរបស់ប្រជាពលរដ្ឋ។ បន្ទាប់ពីបានរៀបចំវេទិកាសាធារណៈប្រចាំឆ្នាំរបស់ស្រុកថ្មគោល បញ្ហាអាទិភាពចម្បងចំនួន ៨ ត្រូវបានលើកឡើងសម្រាប់ក្រុមប្រឹក្សាពិចារណា។ បញ្ហា ២ សំខាន់ៗ ត្រូវបានជ្រើសរើសយកមកដោះស្រាយភ្លាមៗ។ បញ្ហាទី ១ គឺការផ្តល់សេវារដ្ឋបាលពុំទាន់បានរលូន រួមជាមួយនឹងការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការិយាល័យចេញចូលតែមួយ នៅមានកម្រិត និងបញ្ហាទី ២ គឺបញ្ហាទាក់ទងនឹងការគ្រប់គ្រងសំរាម សំណល់រឹង។ ដើម្បីឆ្លើយតបនឹងបញ្ហាទាំង ២ នេះសមាជិកក្រុមប្រឹក្សា បានរៀបចំសេចក្តីព្រាងផែនការសកម្មភាពដោយមានសូចនាករច្បាស់លាស់ និងរៀបចំក្នុងការស្វាបស្ទង់មតិជាមួយប្រជាពលរដ្ឋ។

នៅចុងបញ្ចប់នៃវគ្គប្រឹក្សាយោបល់ ប្រធានក្រុមប្រឹក្សា បានគូសបញ្ជាក់ពីការកើនឡើងនូវការយល់ដឹងអំពីតួនាទីរបស់ក្រុមប្រឹក្សា សមត្ថភាពក្នុងការកំណត់បញ្ហា និងការពង្រឹងប្រសិទ្ធភាពនៃក្រុមការងារ ដែលបានទទួលក្នុងកំឡុងពេលធ្វើការលើកិច្ចការអាទិភាពនេះ។ លោកក៏បានថ្លែងផងដែរថា មេរៀនដែលបានរៀនសូត្រ នឹងនៅតែជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់កិច្ចប្រជុំប្រចាំខែលើកក្រោយៗទៀត។

Co-funded by the European Union

DEUTSCHE ZUSAMMENARBEIT

Implemented by

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

EU DAR

European **U**nion Project for **D**ecentralisation and **A**dministrative **R**eform